ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កងយោធពលខេមរភូមិន្ទ

អគ្គបញ្ជាការ

លេខ.146/99 ...

រាជធានីភ្នំពេញ. ថ្ងៃទី.12.....ខែមីនា...ឆ្នាំ1999..

អគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ

សូមគោរពជូន

សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី

នៃរាជរដ្ឋាភិបាល ព្រះរាជាណាចក្រកម្ពុជា

កម្មវត្ថុ : ស្តីអំពីរបាយការណ៍សភាពការណ៍ព្រំដែនដើមឆ្នាំ ១៩៩៩

- ក្រោយពីសង្គ្រាមផ្ទៃក្នុងរ៉ាំរ៉ៃត្រូវបានបញ្ចប់ទាំងស្រុង ការបង្រួបបង្រួមជាតិ ការឯកភាពជាតិ ត្រូវបានអនុវត្តន៍ជាលើកដំបូងក្នុងក្របខ័ណ្ឌទូទាំងប្រទេស ក្រោមការដឹកនាំដ៏ ឈ្លាសវៃរបស់រាជរដ្ឋាភិបាលអាណត្តិទី២ ។

- ក្នុងគោលបំណងអនុវត្តយុទ្ធសាស្ត្រត្រីកោណរបស់រាជរដ្ឋាភិបាល អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ បានយកចិត្តទុកដាក់លើកិច្ចការការពារបូរណភាពដែនដី ដោយចាត់ទុកជាភារកិច្ចចម្បង ក្នុងគោលបំណងរក្សា និងគ្រប់គ្រងអោយបានដាច់ខាត នូវអធិបតេយ្យភាពនិងកសាងព្រំដែន សន្តិភាពពិតប្រាកដ ជាមួយប្រទេសជិតខាង ។

I. **អំពីសភាពការណ៍ព្រំដែនរួម** :

១. ព្រំដែនកម្ពុជា-វៀតណាម: សរុបមានបាតុភាព ២០លើក ។ ក្នុងនោះនៅខេត្តកំពង់ចាម ១៣លើក។ ខេត្ត ស្វាយរៀង ៣លើក ។ ខេត្តតាកែវ ៤លើក ។

* **ខេត្តកំពង់ចាម** :

- ថ្ងៃទី ០៣ ខែ ០៣ ឆ្នាំ ១៩៩៩ ត្រង់ចំណុច ៤២៤-៩១១ នៅព្រៃប៉ំផ្លាំ កំលាំងទ័ពវៀតណាម ចំនួន ៨នាក់ និងប្រជាជន ១០នាក់ ចូលមកមកកាប់ព្រៃ និងភ្ជួរដីអស់ ៨ហិកតា ។
- ថ្ងៃទី ០៤ ខែ ០៣ ឆ្នាំ ១៩៩៩ ត្រង់ចំណុច ៤៤៤-៩១៤ ព្រែកក្រាយមានប្រជាជនវៀតណាម ៨នាក់ និងកំលាំងប្រដាប់អាវុធ ០៥នាក់ ចូលមកកាប់ព្រៃ និងភ្ជួរដីអស់ ៣ហិកតា ។
- ថ្ងៃទី ០៩ ខែ ០៣ ឆ្នាំ១៩៩៩ នៅត្រង់ចំណុច ១៥២ ០២៤ មានកំលាំងប៉ុស្តិ៍ ៨២៣ វៀតណាម បានដឹកនាំកម្មករជនជាតិចាមចូលមកកាប់ចំការលើផ្ទៃដីជាប់ព្រំដែន ។

- ថ្ងៃទី ១៧ - ១៨ ខែ ០៣ ឆ្នាំ ១៩៩៩ ត្រង់ចំណុច ៣៨៩.៩៥៤ ភូមិជើង ប្រជាជនវៀតណាម ៨នាក់ និងកំលាំងប្រដាប់អាវុធ ៦នាក់ ចូលមកកាប់ព្រៃលើផ្ទៃដី ២ហិកតា ។

- **ថ្ងៃទី ២៧ ខែ ០៣ ឆ្នាំ ១៩៩៩ ត្រង់ចំណុច ៣៨៩.៩៥៥ ខាងកើតប៉ុស្តិ៍បឹងជ្រោង ប្រជាជនវៀតណាម ៣០នាក់ និងកំលាំងប្រដាប់អាវុធ ១២នាក់ ចូលមកកាប់ព្រៃ និងស្វាយចន្ទី ចំនួន ២លើក លើផ្ទៃដី ៨ហិកតាកន្លះ បំផ្លាញស្វាយចន្ទីអស់ ១៥០ដើម ។**

- ថ្ងៃទី២៧ ខែ៣ ឆ្នាំ១៩៩៩ ដដែល ត្រង់ចំណុច ៣៦៤.៩៦៤ ត្រង់ចំណុច៣៧២.៦៦៧ ខាងកើតប៉ុស្តិ៍បេង ប្រជាជនវៀតណាម១៥នាក់ កំលាំងការពារ ៦នាក់ ចូលមកកាប់ព្រៃលើផ្ទៃដី៣០.០០០ម២ ។

- **ថ្ងៃទី ២២ ខែ ០៤ ឆ្នាំ ១៩៩៩ មានកំលាំងទ័ពវៀតណាម បានចូលមកហាមឃាត់ប្រជាពលរដ្ឋខ្មែរយើងមិនអោយធ្វើស្រែ នៅចំណុចកោះអណ្តែត ឃុំត្រពាំងថ្កុង ស្រុកពញាក្រែក លើផ្ទៃដី ៤៣ហិកតា ។**

- ថ្ងៃទី ២៤ ខែ ០៤ ឆ្នាំ ១៩៩៩ ត្រង់ចំណុច ១៦៥.០២៣ ភ្នំបួសតាកុក ភូមិបេង ឃុំ ជាំ ស្រុកមេមត់ មានកំលាំងប៉ុស្តិ៍ ៨២៣ វៀតណាមបានយកត្រាក់ទ័រមួយគ្រឿងចូលមកភ្ជួរដីចំនួន ២លើក ។

- ថ្ងៃទី ២៥ ខែ ០៤ ឆ្នាំ ១៩៩៩ ត្រង់ចំណុច ២៧៩.៩៦៧ ក្នុងភូមិដូងវដ្តទី១ ឃុំ រូង ស្រុកមេមត់ មានកំលាំងប៉ុស្តិ៍ ៨១៩ វៀតណាមបានយកត្រាក់ទ័រមួយគ្រឿងមកភ្ជួរដីក្នុងតំបន់ហាមឃាត់ ។

- ថ្ងៃទី ២៦ ខែ ០៤ ឆ្នាំ ១៩៩៩ ត្រង់ចំណុច ៣៧៩.៩៥៨ ប្រជាជនវៀតណាម ១៥នាក់ និងកំលាំងប្រដាប់អាវុធ ១០នាក់ ចូលមកកាប់ដើមស្វាយចន្ទីអស់ផ្ទៃដី ១ហិកតា បំផ្លាញដើមស្វាយចន្ទីអស់ ១០០ដើម ។

- ថ្ងៃទី ២៩ ខែ ០៤ ឆ្នាំ ១៩៩៩ ត្រង់ចំណុច ៣៦៥.៩៦៥ កំលាំងប៉ុស្តិ៍៨១៩ វៀតណាម៥នាក់ បានយកត្រាក់ទ័រ២គ្រឿងចូលមកភ្ជួរដីចំនួន ៣ហិកតា ។

- ថ្ងៃទី ០៥ ខែ ០៥ ឆ្នាំ ១៩៩៩ ត្រង់ចំណុច ២៧៩.៩៧៣ ក្នុងភូមិសាស្រ្តដូងវដ្តទី១ ឃុំ រូង ស្រុកមេមត់ មានកំលាំងប៉ុស្តិ៍ ៨១៩ វៀតណាមបានយកត្រាក់ទ័រមួយគ្រឿងមកភ្ជួរដីក្នុងតំបន់ហាមឃាត់ ។

- ថ្ងៃទី ១៩ ខែ ០៥ ឆ្នាំ ១៩៩៩ ត្រង់ចំណុច ៣៧៦.៩៦៣ កំលាំងប៉ុស្តិ៍ ៨១៩ វៀតណាម ១១នាក់ ប្រដាប់ដោយអាវុធគ្រប់ដៃ បានយកត្រាក់ទ័រមួយគ្រឿង ចូលមកភ្ជួរដីនៅតំបន់ហាមឃាត់ លើផ្ទៃដី ២ហិកតា កន្លះ និងបំផ្លាញស្វាយចន្ទីអស់ ៣៥ដើម ។

* <u>ខេត្តស្វាយរៀង</u> :

- ថ្ងៃទី ០៨ ខែ ០១ ឆ្នាំ ១៩៩៩ ត្រង់ចំណុច អូដើមថ្កូវ ប្រជាជនវៀតណាម បានចូលមកធ្វើស្រែក្នុងទឹកដីរបស់យើងចំនួន ០៥ហិកតា ។

- ថ្ងៃទី ២៤ ខែ ០១ ឆ្នាំ ១៩៩៩ ត្រង់ចំណុច ០៦៣.០៤៤ ជាប់ទំនប់ត្រពាំងក្រពើ ផ្នែកធារាសាស្ត្រកសិកម្ម វៀតណាមបានចូលមកបោះបង្គោលប្រមាណ ២០បង្គោល បង្គោលនិមួយៗ មានទំហំ ២តឹក បួនជ្រុង កំពស់ ១,៥០ ម ។

- ថ្ងៃទី ១៣ ខែ ០៥ ឆ្នាំ ១៩៩៩ ត្រង់ចំណុច ១៥៤.៩៦៥ក្នុងឃុំចន្ទ្រា នៅតាមបន្ទាត់ព្រំដែន វៀតណាម បានយកត្រាក់ទ័រចូលមកឈូសរំលាយទួល ដែលមានថ្មបង្គោលសីម៉ាចាស់លេខ ៤ ៖

. បង្គោលទី១ មានសរសេរអក្សរ B.L.C.D នៅជ្រុងខាងកើតសរសេរលេខ ០៦៣ នៅជ្រុងខាងជើងដាក់ ថ្ងៃទី ១២ ខែ ១២ ឆ្នាំ ១៩៩៨ នៅជ្រុងខាងលិច ។

. បង្គោលទី២ មានសរសេរអក្សរ T.I.M.N នៅជ្រុងខាងកើតអក្សរ T.I.M ជ្រុងខាងត្បូង អក្សរ C.T.V.D នៅពីលើបង្គោល ។

* <u>ខេត្តតាកែវ</u> :មាន ៤លើក

- ថ្ងៃទី ២៦ ខែ ១២ ឆ្នាំ ១៩៩៨ មានកំលាំងប៉ុស្តិ៍ ៩៤១ ដដែល ៥នាក់ និងកំលាំងសេនាជនឃុំ ចូលមកការពារប្រជាជនគេ អោយមកច្រូសស្រូវក្នុងទឹកដីរបស់យើងត្រង់ចំណុច ០៦៥.៩៤៩ ។

- ថ្ងៃទី ២៩ ខែ ១២ ឆ្នាំ ១៩៩៨ មានកំលាំងវៀតណាម ៦នាក់ ស្លៀកពាក់ស៊ីវិលមានអាវុធគ្រប់ដៃ ចូលមកច្រូសស្រូវក្នុងតំបន់ហាមឃាត់ ។

. ថ្ងៃទី ១៩ ខែ ០៥ ឆ្នាំ ១៩៩៩ កំលាំងប៉ុស្តិ៍ ៩៤១ មានវៀតណាម ១០នាក់ និងសេនាជនភូមិភូហ្វយ ១០នាក់ ទៀតប្រដាប់ដោយអាវុធគ្រប់ដៃចូលមកការពារប្រជាជនគេឱ្យមកធ្វើស្រែ ក្នុងទឹកដីយើងត្រង់ចំណុច ០៦៩.៩៤៩ ។

- វៀតណាមបានជីកព្រែកតាមបន្ទាត់ព្រំដែនពីកើតទៅលិច ។ បើតាមទម្លាប់ប្រជាជនថា : ព្រែកជីក នេះវៀតណាមជីកនៅឆ្នាំ១៩៧៩ ចូលដីខ្មែរ ១២៧០ម ដោយគិតពីព្រែកជីក(វិនតេ ដែលបានជីកតាំង ពីជំនាន់អាណានិគមនិយមបារាំង ) ។

២. <u>ព្រំប្រទល់កម្ពុជា_ថៃ</u> : មានបាតុភាព ១០លើក ខុសៗគ្នា ជាក់ស្តែង

* <u>ទិសឃោចភូមិភាគទី៣</u> :

- នៅភូមិចាំយាម_ហាត់លឹក TT(74.88) ភាគីថៃបានរំកិលបង្គោលព្រំដែនលេខ៧៣ ពីចំណុចដើមចូលមកក្នុងទឹកដីយើងប្រមាណ ៧០ម ។ ក្រុមហ៊ុនកាស៊ីណូនៅតំបន់នេះបានសាងសង់ថ្មីៗ ជាប់ព្រំដែន ក្នុងនោះមានទំនប់ទឹកមួយដែលថៃបានប្រកាសមិនអោយយើងសង់បន្តទៀតគេចោទថារំលោភលើដែនទឹករបស់គេ ទន្ទឹមនេះក៏មានការបំផ្លាញភ្នំនៅចំណុចខ្ពស់ 199TT (74.89) ដែលជាទីកំណត់ព្រំដែននៅលើកោះកូត តាមសន្ធិសញ្ញាឆ្នាំ១៩០៧ របស់ភាគីបារាំង_សៀម បើមិនទប់ស្កាត់ទាន់ពេលទេ នាំអោយមានការបាត់បង់ចំណុចខ្ពស់នេះ ផ្តល់ផលពិបាកក្នុងការកំណត់ព្រំដែនគោក និងទឹក រវាងប្រទេសទាំងពីរ ។

- ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ នាវាចំបាំងថៃ ធ្វើសកម្មភាពការពាររដ្ឋអំណាចឃុំរបស់គេឈ្មោះកំណាន់ចូត ធ្វើការបោះបង្គោលព្រំដីចូលមកក្នុងទឹកដីព្រះរាជាណាចក្រកម្ពុជា ក្នុងភូមិសាស្ត្រ ភូមិចាំយាម ស្រុកមណ្ឌលសីមា ខេត្តកោះកុង ។

* **យោធភូមិភាគទី ៥ :**

<u>តំបន់បឹងត្រកួន TA (68.46)</u> :

- ថៃ បានស្លាបនាផ្លូវកៅស៊ូប្រវែង ៨០០ ម ចូលជ្រៅមកក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ថែមទាំងបង្វិតបង្គោលព្រំដែនមកដាក់នៅចុងផ្លូវថ្មីនេះទៀត ។

- នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ភាគីថៃ បានសាងសង់ផ្ទះប្រចាំការមួយនៅតំបន់ចុងផ្លូវដដែល TA (68.46) តែយើងបានតវ៉ាច្រើនដង ថៃក៏ផ្អាកការសាងសង់នោះបណ្តោះអាសន្នរហូតដល់សព្វថ្ងៃ ។

<u>តំបន់ចោមប៉ែត</u> :

- នៅច្រកចោមប៉ែត ក្រុមហ៊ុន អានកូ បានសាងសង់សំណង់ (កាស៊ីណូ) និងចាក់ដីលុបផ្លូវរថភ្លើង នៅជាប់នឹងច្រកព្រំដែន (អូជ្រៅ) ដែលមានបណ្តោយ ៣៧០ម ទទឹងប្រមាណ ២០០ម ។

<u>តំបន់ភ្នំប៉ែត្រ</u> :

- នៅច្រកភ្នំប្រា TA (6242.4 ) ភូមិក្តិកថ្ម ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ថៃរំលោភ ចូលមកក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចំងាយប្រមាណពី ៦០០ម-៨០០ម ។

<u>តំបន់ឡាក់ 27 TA ( 80.71 )</u> :

- ថ្ងៃទី២០ ខែ ០៤ ឆ្នាំ ១៩៩៩ ទាហានថៃប្រមាណ ២០០នាក់ រួមទាំងមានរថពាសដែក ចំនួន ០៤គ្រឿង បានឆ្លងចូលមកក្នុងដីយើង ហើយដេញកំលាំងកងពលលេខ ៧ អតីតកំលាំងរបស់លោក ខៀវ វិរៈ ព្រមទាំងដុតបំផ្លាញជំរកទាហានអស់ចំនួន ២៥ខ្នង ។

* **<u>យោធភូមិភាគទី ៤</u> :**

<u>តំបន់ជប់គគី UA (05.85)</u> :

- ក្នុងខែ ០៤ និង ០៥ ឆ្នាំ ១៩៩៩ ថៃបានឈូសដីចូលក្នុងព្រំដែនយើងចំងាយប្រមាណ ៦០០មនៅចំណុច UA ( 04.5 , 84.8 ) កងពលលេខ១៥របស់យើង បាននិយាយតវ៉ាជាមួយភាគី ថៃនៅស្ទូរិន ថៃបានប្រមូលគ្រឿងចក្ររបស់គេឈប់បណ្តោះអាសន្ន ។

<u>**តំបន់ប្រាសាទព្រះវិហារ**</u> :

- តាមរបាយការណ៍របស់កងពលលេខ២ និងខេត្តព្រះវិហារ បានអោយដឹងថា ភាគីថៃបានហាមមិន ឱ្យយើងសង់ផ្សារនៅដីរបស់យើង និងហាមមិនឱ្យយើងដោះមីននៅខាងលិចជណ្តើរប្រាសាទ

តំបន់ចំណុចកំពស់ ៥០០ (70.92) :

- មានការទាស់ដណ្តើមគ្នាកាន់កាប់តំបន់នេះព្រោះមុនពេលសមាហរណកម្មចុងក្រោយ តំបន់នេះកាន់កាប់ដោយភាគីខ្មែរក្រហម ។

៣. ព្រំដែនកម្ពុជា-ឡាវ : សរុបមានចាតុភាគ ១លើក

- នៅស្រែវែងស្ថិតនៅក្នុងស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែងចំណុចXA (28.52) ទល់មុខស្រុកមៀងខុង ខេត្តចំប៉ាសាក់ (ឡាវ) មានប្រជាជនឡាវមករស់នៅទីនោះតាំងពីសម័យសង្គមរាស្ត្រនិយមក្នុងឆ្នាំ១៩៦៤ ប៉ុន្តែរបបប៉ុលពតឆ្នាំ១៩៧៥-១៩៧៩ ពួកនេះបានចូលទៅរស់នៅក្នុងទឹកដីឡាវវិញ លុះដល់ឆ្នាំ១៩៧៩ រហូតមកដល់បច្ចុប្បន្ន ពួកគេបានត្រឡប់មករស់នៅចំណុចនេះវិញ ។

## II. ការដោះស្រាយបញ្ហាព្រំដែនជាមួយបណ្តាប្រទេសជិតខាង :

១. ជាមួយភាគីថៃ :

- យោងតាមអនុក្រឹត្យលេខ ៦៧ ចុះថ្ងៃទី១៩/០៩/១៩៩៥ របស់រាជរដ្ឋាភិបាល ស្តីអំពីបង្កើតគណកម្មការព្រំដែនទូទៅ និងគណកម្មការរក្សាសន្តិភាពព្រំដែនទូទៅ ។ អគ្គបញ្ជាការបានចាត់តាំងគណកម្មការព្រំដែនថ្នាក់យោធភូមិភាគ,អង្គភាពជំនាញ និងនាយទាហានប្រចាំការនៅតាមបណ្តាច្រកដែលបានកំណត់រួមមាន : ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ នៅច្រកប៉ោយប៉ែត និងក្រុមទំនាក់ទំនងការងារ តាមច្រកព្រំដែន ២៣ក្រុម ។

- ឈរលើស្មារតីសន្តិភាព-មិត្តភាពជាមួយប្រទេសជិតខាង គណកម្មការរក្សាសន្តិភាពព្រំដែនទូទៅ និងក្រុមការងារព្រំដែនគ្រប់ថ្នាក់ដែលបានចាត់តាំងហើយ បានខិតខំព្យាយាមដោះស្រាយវិវាទខាងលើ ដោយចាត់តាំងប្រតិភូគ្រប់ថ្នាក់ជួបចរចារជាមួយសមភាគីថៃនៅតាមទីកន្លែង និងពេលវេលាកើតហេតុ ជៀសវាងបានទាំងស្រុងការប៉ះទង្គិចដោយអាវុធ ដូចជា :

* ករណីបឹងត្រកួន

ឯកឧត្តមអគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ បានធ្វើការចរចារផ្ទាល់ជាមួយអគ្គបញ្ជាការថៃ កាលពីថ្ងៃទី០៧-០៣-១៩៩៩ បានបញ្ឈប់ការសាងសង់សំណង់ប៉ុស្តិ៍ព្រំដែនថៃនៅច្រកបឹងត្រកួន រហូតមកដល់សព្វថ្ងៃ ។

* ករណីឡាក់ ២៧ :

អគ្គមេបញ្ជាការបានចាត់តាំងតំណាងទីចាត់ការព្រំដែន និងតំណាងយោធភូមិភាគ៥ កងពលលេខ៧ បានទៅជួបចរចារជាមួយភាគីថៃ ដោះស្រាយដោយសន្តិភាព ។

២. <u>ការដោះស្រាយជាមួយភាគីវៀតណាម-ឡាវ</u> :

- កន្លងមកអគ្គបញ្ជាការ កងយោធពលខេមរភូមិន្ទ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ធ្វើទស្សនៈកិច្ចជាផ្លូវការ នៅសាធារណៈរដ្ឋសង្គមនិយមវៀតណាម និងសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ពីថ្ងៃទី២០-២៦ ខែ០៧ ឆ្នាំ១៩៩៩ក្នុងគោលបំណងពង្រឹងសហប្រតិបត្តិការយោធា និងលើកកំពស់ចំណងមិត្តភាពជាមួយបណ្តាប្រទេសជិតខាង ។

- ក្នុងអំឡុងពេលទស្សនៈកិច្ចនេះ សមភាគីទាំងពីរបានឯកភាពជាគោលការណ៍រួម ក្នុងការដោះស្រាយរាល់ការវិវាទព្រំដែនដោយសន្តិវិធី គោរពតាមបណ្តាកិច្ចព្រមព្រៀង អនុសញ្ញា-សន្ធិសញ្ញា ដែលគណកម្មការព្រំដែនជាតិបានឯកភាពគ្នា ។

- ថ្នាក់ដឹកនាំយោធាទាំង៣ប្រទេសបានឯកភាពគ្នាទៀតថា និងខិតខំផ្លាស់ប្តូរប្រតិភូថ្នាក់យោធាភូមិភាគរវាងគ្នានិងគ្នា ៦ខែម្តង ថ្នាក់ខេត្ត ៣ខែម្តង ដើម្បីពង្រឹងសហប្រតិបត្តិការមិត្តភាពសន្តិភាពតាមបណ្តោយព្រំដែន ជៀសវាងដាច់ខាតការប្រឈមមុខដោយអាវុធ ។

## III. <u>ការវាយតំលៃ សន្និដ្ឋាន និងបទពិសោធន៍</u> :

១. <u>ការវាយតំលៃ</u> :

- បាតុភាពព្រំដែនដែលកើតមានឡើងកន្លងមកបណ្តាលមកអំពី :

ក/ ឯកសារដែលអាណានិគមបារាំងបន្សល់ទុកមកពុំទាន់មានភាពសុក្រិត្យនៅមានចំណុចល្អ និងចំណុចអាក្រក់ខ្លះដែលត្រូវធ្វើការកែសំរួលជាមួយបណ្តាប្រទេសជិតខាង ។

<u>ឧទាហរណ៍</u> ខ្សែប្រេវិយេពុំមែនជាខ្សែព្រំដែន គ្រាន់ជាខ្សែគ្រប់គ្រងរដ្ឋបាលប៉ុណ្ណោះ ។

- ជាមួយភាគីថៃ បារាំងបានបន្សល់ទុកនៅឯកសារ និងផែនទីព្រំដែនអមសន្ធិសញ្ញា 1904 -1907 ។ ឯកសារនេះមានភាពច្បាស់លាស់ខាងផ្លូវច្បាប់ជាងខ្សែប្រេវិយេ ។

ខ/ ដោយសារសង្គ្រាមផ្ទៃក្នុងរ៉ាំរ៉ៃអូសបន្លាយរយៈពេលយូរ បញ្ហាព្រំដែនពុំទាន់បានប្រមូលផ្តុំដោះស្រាយជាមួយបណ្តាប្រទេសជិតខាង ។ ភូមិករដែលតាមជាយដែន ត្រូវជម្លៀសចេញ ហេដ្ឋារចនាសម្ព័ន្ធត្រូវបំផ្លាញ ពិសេសក្នុងរបបប្រល័យពូជសាសន៍ប៉ុលពតប្រជាជនត្រូវបាត់បង់នូវកម្មសិទ្ធិដីធ្លី ។

គ/ បណ្តាលមកពីលក្ខណៈបច្ចេកទេសនៃផែនទីមិនទាន់មានភាពសុក្រិត្យនិងបច្ចេក វិទ្យាខ្ពស់នៅឡើយ បង្កឱ្យមានការលំបាកដល់ការកំណត់ទីតាំងព្រំសីម៉ា ។

ឃ/ បណ្តាលមកពីការរីករាលដាលនៃប្រជាជននៃបណ្តាប្រទេសជិតខាង

២. <u>ការសន្និដ្ឋាន</u>

ពិនិត្យជារួមរយៈពេល៦ខែ ដើមឆ្នាំ១៩៩៩ នៅតាមបណ្តោយព្រំដែនជាមួយបណ្តា

ប្រទេសជិតខាងមានភាពទំនាស់ជាច្រើនលើក ច្រើនសារ លើច្រើនតំបន់ ។ ហេតុការណ៍នេះអាចអោយយើងសន្និដ្ឋានបានថា : ក្រោយពេលដែលយើងបានរួបរួមគ្នា បណ្តាប្រទេសជិតខាងក៏រៀបចំនយោបាយ ព្រំដែនរបស់គេឡើងវិញដែរ ។

៣. <u>បទពិសោធន៍</u>

ក្នុងរយៈពេលដំណើរការដោះស្រាយ រាល់បាតុភាពដែលកើតមានឡើងតាមបណ្តោយព្រំដែន អគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ ដកស្រង់បទពិសោធន៍មួយចំនួន :

ក/ ការរៀបចំគណកម្មការរក្សាសន្តិភាពព្រំដែនទូទៅកម្ពុជា-ថៃ បង្កលក្ខណៈងាយស្រួលក្នុងការទប់ស្កាត់ទាន់ពេលវេលា បណ្តាបាតុភាពវិវាទ រវាងប្រទេសទាំងពីរ ។

ខ/ តួនាទីរបស់យោធាទាំង២ប្រទេស នៅតាមព្រំដែនមានសារៈសំខាន់ដល់ការដោះស្រាយរាល់ វិវាទតាមព្រំដែន ។

គ/ ទីកន្លែងណាដែលមានភូមិករប្រជាជនរស់នៅតាមបណ្តោយព្រំដែនកុះករ គឺទីកន្លែងនោះពុំសូវមានទំនាស់ព្រំដែនទេ ។

ឃ/ នៅទីកន្លែងណាដែលមានកងកំលាំងប្រដាប់អាវុធរបស់យើងឈរជើង មានការងាយស្រួលក្រួតពិនិត្យ ដោះស្រាយ ។

<u>សំណូមពរ</u>

១.រាជរដ្ឋាភិបាលមានផែនការកសាងហេដ្ឋារចនាសម្ព័ន្ធនៅបណ្តាមូលដ្ឋានជាប់ព្រំដែន ដើម្បីគួបផ្សំការងារការពារប្រទេស និងអភិវឌ្ឍន៍ប្រទេសជាតិ ។

២.ចំពោះបញ្ហាដោះមីនតាមបណ្តោយព្រំដែន ត្រូវមានការឯកភាពជាមួយគណកម្ម-ការព្រំដែន និងក្រសួងការពារជាតិ ដើម្បីធានាឱ្យបានទាំងផ្នែកបច្ចេកទេសទាំងផ្នែកសន្តិសុខជាតិ ។

៣.យកចិត្តទុកដាក់អភិវឌ្ឍន៍តំបន់ព្រំដែនច្រើនជាងកន្លែងផ្សេងៗ

៤.រាជរដ្ឋាភិបាលពង្រឹងសមត្ថភាព និងផ្តល់លទ្ធភាពគ្រប់គ្រាន់ឱ្យគណៈកម្មការព្រំដែនជាតិ បំពេញកិច្ចការបានល្អ ។

៥.រាជរដ្ឋាភិបាលចំណាយថវិកាដើម្បីកសាងទីកន្លែងចាំបាច់មួយចំនួន នៅតាមព្រំដែន (គំរោងកសាងលំអិត និងធ្វើជូននៅពេលក្រោយ) ។

៦.រាជរដ្ឋាភិបាលមានគោលនយោបាយច្បាស់លាស់ចំពោះកងកំលាំងប្រដាប់អាវុធ និងប្រជាជន ដើម្បីលើកទឹកចិត្តដល់អ្នកដែលស្ម័គ្រចិត្តទៅរស់នៅតាមបណ្តោយព្រំដែន ។

៧.រាល់គំរោងការសាងសង់យុទ្ធសាស្ត្រសំខាន់ៗនៅព្រំដែន ស្នើអោយមានការរួមយោបល់ពិភាក្សារបស់អគ្គមេបញ្ជាការ ក្រសួងការពារជាតិ គណៈកម្មការព្រំដែនជាតិ ។

៨.ពង្រាយកំលាំងយោធាព្រំដែន និងនគរបាល ទៅព្រំដែនជំនួសអោយកំលាំងទ័ពស្រួច ។

៩.តាមព្រំដែន កន្លែងណាដែលភាគីទាំងសងខាងបានឯកភាពគ្នារួច ត្រូវបោះបង្គោលអោយហើយឆាប់ មិនត្រូវរងចាំរហូតដល់មានការឯកភាពទាំងស្រុង ទើបបោះបង្គោលនោះទេ

១០.ការពង្រឹងកងទ័ពអោយបានរឹងមាំ ត្រូវធ្វើជាចាំបាច់ មិនអាចមើលស្រាលសភាព.ការណ៍បានឡើយ ។

អាស្រ័យដូចបានរាយការណ៍ជូនខាងលើ សូមសម្តេចនាយករដ្ឋមន្ត្រី មេត្តាជ្រាបជារបាយការណ៍ ។

សូមសម្តេចនាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។៚

អគ្គមេបញ្ជាការ

នាយឧត្តមសេនីយ៍.កែ_គឹមយ៉ាន

ចម្លងផ្ញើជូន

- ក្រសួងការពារជាតិ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គណៈកម្មាធិការព្រំដែនជាតិ

} ដើម្បីជូនជ្រាប

- ឯកសារ.កាលប្បវត្តន៍




គំនូសព្រំប្រទល់ដែលវៀតណាមរំលោភ គូរក្រៅផ្លូវការដោយរស្មីកម្ពុជា